**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

នៅព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានអនុញ្ញាតឲ្យឯកឧត្តម Marek Libricky ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែកប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃចំណងមិត្តភាពជាប្រពៃណី រវាងកម្ពុជា និងឆែក ដែលមានតាំងពីទស្សវត្សទី៥០កន្លងមក ដែលនៅពេលនោះ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានរួមចំណែកបង្កើតឡើង និងពង្រឹងពង្រីកទំនាក់ទំនងនេះជាបន្តបន្ទាប់ រហូតមកដល់សព្វថ្ងៃនេះ។ ទំនាក់ទំនងទ្វេភាគីនេះ ត្រូវបានបន្តជំរុញធ្វើឲ្យកាន់តែស៊ីជម្រៅ និងជិតស្និទ្ធបន្ថែមទៀតដោយ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ **ឯកឧត្តម** បានរំលឹកផងដែរថា កម្ពុជាចងចាំមិនភ្លេចចំពោះការជួយឧបត្ថម្ភ គាំទ្ររបស់សាធារណរដ្ឋឆែក នៅក្នុងទស្សវត្សទី៨០ ក្នុងពេលដែលកម្ពុជាជួបការលំបាក ក្រោយសង្គ្រាម និងអំពើប្រល័យពូជសាសន៍។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការពេញចិត្តចំពោះទំនាក់ទំនងនៃប្រទេសទាំងពីរ ជាពិសេសការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់រវាងថ្នាក់ដឹកនាំប្រទេសទាំងពីរនាពេលកន្លងមក។ ដើម្បីតភ្ជាប់ទំនាក់ទំនងនេះឲ្យបានខ្លាំងក្លាថែមទៀត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋឆែក នៅក្នុងខែតុលា ខាងមុខនេះ។

**ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋឆែក។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានបញ្ជាក់ថា សាធារណរដ្ឋឆែកចាត់ទុកកម្ពុជាជាមិត្តដ៏ជិតស្និទ្ធ ហើយ**ឯកឧត្តម** នឹងខិតខំធ្វើយ៉ាងណា ដើម្បីជំរុញឲ្យទំនាក់ទំនងរវាងប្រទេសទាំងពីរឲ្យកាន់តែជិតស្និទ្ធបន្ថែមទៀត និងមានកិច្ចសហប្រតិបត្តិការល្អលើគ្រប់វិស័យ ជាពិសេសនៅក្នុងឱកាសទស្សនកិច្ចរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ទៅសាធារណរដ្ឋឆែកនាពេលខាងមុខនេះ។

**ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានបញ្ជាក់ថា កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសាធារណរដ្ឋឆែកនៅពេលខាងមុខនេះ គឺផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ប្រទេសឆែកបានជ្រើសរើសយកកម្ពុជា ជាប្រទេសមួយនៅក្នុងចំណោមប្រទេស៦ សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ ដោយផ្អែកទៅលើគោលការណ៍ភាពជាដៃគូ។ នេះជាកិច្ចសហប្រតិបត្តិការថ្មីមួយ ដែលខុសអំពីកិច្ចសហប្រតិបត្តិការផ្តល់ជំនួយអភិវឌ្ឍន៍កន្លងមក។

ឥ.

**ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានលើកឡើងថា នឹងមានគម្រោងកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើន រួមមាន សុខាភិបាល កសិកម្ម ការពារជាតិ អាកាសចរណ៍ បរិស្ថាន ទឹកស្អាត ស្ថានីយ៍ចម្រោះទឹកកខ្វក់ ទេសចរណ៍បៃតង។ល។ និងសម្រាប់វិស័យសុខាភិបាល ភាគីឆែកមានគម្រោងបើកមន្ទីរពេទ្យទំនើបមួយ នៅពេលខាងមុខ ហើយដែលបច្ចុប្បន្ននេះ ភាគីឆែកកំពុងតែពិភាក្សាលើកិច្ចសហប្រតិបត្តិការនេះ ជាមួយ នឹងភាគីកម្ពុជាក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការណ៍អភិវឌ្ឍថ្មីនេះ ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ភាគីឆែក ចំពោះការលុបចោលនូវបំណុល ដែលកម្ពុជាជំពាក់ប្រទេសឆែកកន្លងមក និងបានបង្វែរបំណុលនោះមួយចំនួនទៅជាជំនួយសម្រាប់ការ អភិវឌ្ឍវិញ ដែលនេះជាចំណុចមួយល្អគួរប្រទេសផ្សេងទៀតយកគំរូតាម និងបានសំដែងការគាំទ្រចំពោះ កិច្ចសហប្រតិបត្តិការអភិវឌ្ឍថ្មីដែលផ្អែកលើភាពជាដៃគូលើកឡើងដោយភាគីឆែក។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍ថា កម្ពុជាមានវិស័យអាទិភាពប្រកបដោយ សក្តានុពលច្រើនក្នុងការវិនិយោគផ្ទាល់ពីវិនិយោគិនបរទេស។ **ឯកឧត្តម** បានស្វាគមន៍គំនិតផ្តួចផ្តើមដ៏ល្អ របស់ភាគីឆែកក្នុងការរួមគ្នាជាដៃគូសាងសង់មន្ទីរពេទ្យមួយដែលមានគុណភាពនៅប្រទេសកម្ពុជា ដើម្បី លើកកំពស់ការថែទាំសុខភាពរបស់ប្រជាជន។ ចំពោះវិស័យថាមពល អាស្រ័យដោយកម្ពុជាបានចុះហត្ថ លេខាលើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលឡាវ ដើម្បីទិញថាមពលសរុប២៩០០មេហ្គាវ៉ាត់ដើម្បីបំពេញការ ខ្វះខាតអគ្គិសនីនៅក្នុងប្រទេសនោះ ភាគីឆែកអាចសិក្សាពីការសាងសង់ខ្សែបណ្តាញអគ្គិសនីពីប្រទេស ឡាវមកកម្ពុជា និងពិនិត្យលទ្ធភាពវិនិយោគលើថាមពលកកើតថ្មី។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យ កសិកម្មដែលផ្តោតទៅលើការវេចខ្ចប់ និងម៉ាស៊ីនកិនស្រូវដ៏មានគុណភាពសំរាប់ការផលិតអង្ករ បំរើអោយ ការនាំចេញ។ វិស័យទេសចរណ៍បៃតងក៏ជាវិស័យមួយដែលអាចទាក់ទាញភ្ញៀវមកពីទ្វីបអឺរ៉ុបនិងអាមេរិក។ **ឯកឧត្តម** បានសម្តែងការជឿជាក់ថាកិច្ចសហប្រតិបត្តិការជាមួយភាគីឆែក ក្នុងក្របខណ្ឌថ្មីនេះនឹងនាំនូវ ថាមភាពថ្មីៗ បន្ថែមទៀតសំរាប់ការអភិវឌ្ឍប្រទេសកម្ពុជា។

**ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានបញ្ជាក់ថា ភាគីឆែកក៏មានមោទនភាពដែរ ដែលបានសហការ ជាមួយនឹងកម្ពុជាលើវិស័យជាច្រើននាពេលកន្លងមក ហើយនឹងត្រៀមខ្លួនជាស្រេចដើម្បីសហការជាបន្ត ទៀត សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍក្នុងភាពជាដៃគូ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល៕

ថ្ងៃអាទិត្យ ៩រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩